00644251

E48

# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អជសដ

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក អៀង សារី

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១១

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ **សាធារណៈ / Public**

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

**បណ្ដឹងឧទ្ធរណ៍បន្ទាន់ តាមវិធាន ៨៩ របស់ អៀង សារី (វិធាន ៨៩(១)(គ)**

<u>ដាក់ដោយ៖</u>

**សហមេធាវីរបស់លោក អៀង សារី**

លោក អាង ឧត្តម

លោក Michael G. KARNAVAS

<u>ផ្ញើជូន៖</u>

**អង្គជំនុំជម្រះសាលាដំបូង**

ចៅក្រម និល ណុន

ចៅក្រម ធូ មណី

ចៅក្រម យ៉ា សុខន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម Jean-Marc LAVERGNE

ចៅក្រមបំរុង យូ ឧត្តរ៉ា

ចៅក្រមបំរុង Claudia FENZ

<u>ផ្ញើជូន៖</u>

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Andrew CAYLEY

**ក្រុមមេធាវីការពារក្ដីទាំងអស់**

**ឯកសារដើម**

DOCUMENT RECEIVED/DOCUMENT REÇU

ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 14 / 02 / 2011

ម៉ោង (Time/Heure): 15:45

មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

អនុលោមតាមវិធាន ៨៩(១)(គ) នៃវិធានផ្ទៃក្នុងរបស់ អវតក លោក អៀង សារី តាមរយៈសហមេធាវីរបស់គាត់ ("មេធាវីការពារក្ដី") តទៅនេះសូមដាក់បណ្ដឹងអញ្ញត្រកម្មនេះចំពោះការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង "បដិសេធលើសំណើទាំងអស់ ដែលស្នើសុំពន្យារកាលបរិច្ឆេទចុងក្រោយសម្រាប់ដាក់សម្ភារៈដើម្បីត្រៀមរៀបចំសវនាការ" ហើយ"នៅក្នុងរយៈពេលមួយសមស្រប អង្គជំនុំជម្រះសាលាដំបូងនឹងបញ្ជាក់ថា តើសារណាបន្ថែមណាខ្លះដែលនឹងតម្រូវឱ្យដាក់ នឹងទទួលយកបន្ទាប់ពីអង្គបុរេជំនុំជម្រះចេញសេចក្ដីសម្រេចដែលមានសំអាងហេតុពេញលេញរបស់ខ្លួន ("សេចក្ដីសម្រេច")[1]។ បណ្ដឹងអញ្ញត្រកម្មនេះត្រូវបានធ្វើឡើងជាចាំបាច់ ដោយសារសេចក្ដីសម្រេចនេះ មិនគោរពវិធានបញ្ញត្តិ[2]។ សេចក្ដីសម្រេចនេះប៉ះពាល់ដល់សិទ្ធិរបស់លោក អៀង សារី ដើម្បីទទួលបានការត្រៀមរៀបចំការការពារ, ទទួលបាននូវពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីត្រៀមរៀបចំការការពារ និងសិទ្ធិត្រូវបានជំនុំជម្រះក្ដីយ៉ាងឆាប់រហ័ស ។ សេចក្ដីសម្រេចនេះតម្រូវឱ្យមេធាវីការពារក្ដីដាក់អញ្ញត្រកម្ម ដោយពុំមានឱកាសវិភាគសំអាងហេតុរបស់អង្គបុរេជំនុំជម្រះ ទៅលើសាលដីការបស់ខ្លួនលើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ[3]។ ដោយបង្ខំចិត្តត្រូវលើកអញ្ញត្រកម្មជាអរូបី មេធាវីការពារក្ដីមិនអាចធ្វើអ្វីក្រៅពីជំទាស់ចំពោះការមិនគោរពវិធានបញ្ញត្តិនៅដំណាក់កាលនេះនៃដំណើរការនីតិវិធី ព្រោះមានតែការធ្វើបែបនេះទេ ដែលសមស្របជាមួយកាតព្វកិច្ចរបស់មេធាវីការពារក្នុងការពារក្ដីប្រកបដោយវិរិយភាព ដើម្បីធានាសិទ្ធិទទួលបានការជំនុំជម្រះក្ដីដោយយុត្តិធម៌របស់លោក អៀង សារី[4] ។

---

[1] *ករណី អៀង សារី* ០០២/១៩-០៩-២០០៧/អវតក/អជសដ, អនុស្សរណៈអន្តរការិយាល័យរបស់ Susan Lamb មន្ត្រីច្បាប់ជាន់ខ្ពស់នៅអង្គជំនុំជម្រះសាលាដំបូង ផ្ញើទៅភាគីទាំងអស់នៅក្នុងករណី០០២៖ ការជូនដំណឹងជាមុនអំពីសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើញត្តិ: E14, E15, E9/2, E9/3, E/24 and E27, ចុះថ្ងៃទី៣ ខែ កុម្ភៈ ឆ្នាំ២០១១, E35, ERN: 00642291-00642292 ("អនុស្សរណៈអន្តរការិយាល័យ")។

[2] វិធាន ៤៨ ចែងថា "កិច្ចស៊ើបសួរ ឬ កិច្ចរបស់អង្គជំនុំជម្រះអាចត្រូវបានចាត់ទុកជាមោឃៈតែចំពោះករណីមិនគោរពវិធានបញ្ញត្តិដែលធ្វើឱ្យប៉ះពាល់ដល់សិទ្ធិរបស់ភាគី ដែលដាក់ពាក្យបណ្ដឹងសុំប៉ុណ្ណោះ" ។ វិធាន ៨៩(១)(គ) ចែងថាអញ្ញត្រកម្មអាចត្រូវបានលើកឡើងទាក់ទងនឹងមោឃភាពនីតិវិធីដែលត្រូវបានធ្វើបន្ទាប់ពីមានដីកាដំណោះស្រាយ ។

[3] *ករណី អៀង សារី* ០០២/១៩-០៩-២០០៧/អវតក/កសចស(អបជ៧៥) សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៣ ខែមករា ឆ្នាំ ២០១១ D427/1/26, ERN: 00634887-00634891 "សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី") ។

[4] សហមេធាវីមានកាតព្វកិច្ចការពារលោក អៀង សារី ប្រកបដោយវិរិយភាព ។ ភារកិច្ចនេះតម្រូវឱ្យមេធាវីការពារក្ដីការពារសិទ្ធិ និងផលប្រយោជន៍របស់លោក អៀង សារី ប្រកបដោយវិរិយភាព ធ្វើយ៉ាងដូច្នេះ គឺដើម្បីធានាថាគាត់ទទួលបានការជំនុំជម្រះក្ដីដោយយុត្តិធម៌ ។ ការពិភាក្សាលើកលក្ខខណ្ឌតម្រូវនៃការការពារប្រកបដោយការយកចិត្តទុកដាក់ទាក់ទងនឹងសិទ្ធិទទួលបានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់សម្រាប់ការត្រៀមរៀបចំការការពារ អ្នកនិពន្ធម្នាក់បានធ្វើកត់សំគាល់ថា

# I សាវតារ

១. នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ កសចស ចេញដីកាដំណោះស្រាយក្នុងករណី០០២[5] ។

២. នៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១០ មេធាវីការពារក្តីដាក់ការជូនដំណឹងពីបណ្តឹងឧទ្ធរណ៍[6] និងដាក់សំណើសុំបន្ថែមចំនួនទំព័រសម្រាប់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ[7] ។

៣. នៅថ្ងៃទី១ ខែតុលា ឆ្នាំ២០១០ សំណើនេះត្រូវបានទទួលយកដោយអង្គបុរេជំនុំជម្រះ[8] ។

៤. នៅថ្ងៃទី ២៥ ខែតុលា ឆ្នាំ ២០១០ មេធាវីការពារក្តីបានដាក់បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយនៅអង្គបុរេជំនុំជម្រះ ទៅលើមូលដ្ឋានយុត្តាធិការចំនួន ១១[9] ។

៥. នៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១ អង្គបុរេជំនុំជម្រះបានចេញសាលដីការបស់ខ្លួន លើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ព្រមជាមួយនឹងការចេញការសំអាងហេតុដើម្បីគាំទ្រលើសាលដីកានេះ

---

"ទាក់ទងនឹងពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ មេធាវីការពារក្តី ត្រូវបានគេរំពឹងទុក និងតម្រូវឱ្យមានការយកចិត្តទុកដាក់នូវកម្រិតជាក់លាក់មួយ ។ <u>មេធាវីការពារក្តីអាចនឹងតវ៉ាអំពីការរំលោភបំពានលើសិទ្ធិរបស់ពួកគេបាន លុះត្រាតែគេបានធ្វើអ្វីៗដែលបានតម្រូវ</u> ដោយច្បាប់ជាតិ ដើម្បីទទួលនូវ (ការបន្ថែម) នូវពេលវេលាជាបន្តបន្ទាប់។ អត្ថបទរបស់ ក្រោមចំណងជើងថា សិទ្ធិមនុស្សនៅក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ HUMAN RIGHTS IN CRIMINAL PROCEEDINGS 214 (Oxford University Press, 2005) (គូសបញ្ជាក់បន្ថែម)។

[5] *ករណី អៀង សារី* ០០២/១៩-០៩-២០០៧/អវតក/កសចស ដីកាដំណោះស្រាយ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ D427, ERN: 00604508-00605246 ("ដីកាដំណោះស្រាយ") ។

[6] *ករណី អៀង សារី* ០០២/១៩-០៩-២០០៧/អវតក/កសចស(អបជ៧៥) សៀវភៅចុះបណ្តឹងឧទ្ធរណ៍របស់មេធាវី អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១០ D427/1 ERN: 00607319-00607321 ។

[7] *ករណី អៀង សារី* ០០២/១៩-០៩-២០០៧/អវតក/កសចស(អបជ៧៥) សំណើជាបន្ទាន់របស់ អៀង សារី សុំបន្ថែមចំនួនទំព័រកំណត់ ដើម្បីប្តឹងឧទ្ធរណ៍ប្រឆាំងនឹងបញ្ហាយុត្តាធិការ ដែលបានលើកឡើងនៅក្នុងដីកាដំណោះស្រាយ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១០ D427/1/1, ERN: 00607672-00607674 ។

[8] *ករណី អៀង សារី* ០០២/១៩-០៩-២០០៧/អវតក/កសចស(អបជ៧៥) សេចក្តីសម្រេចលើសំណើជាបន្ទាន់របស់ អៀង សារី សុំបន្ថែមចំនួនទំព័រកំណត់ ដើម្បីប្តឹងឧទ្ធរណ៍ប្រឆាំងនឹងបញ្ហាយុត្តាធិការដែលបានលើកឡើងនៅក្នុងដីកាដំណោះស្រាយ ចុះថ្ងៃទី១ ខែតុលា ឆ្នាំ២០១០ D427/1/3, ERN: 00611380-00611383 ។

[9] សូមមើល *ករណី អៀង សារី* ០០២/១៩-០៩-២០០៧/អវតក/កសចស(អបជ៧៥) បណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១០ D427/1/6, ERN: 00617486-00617631 ("បណ្តឹងឧទ្ធរណ៍")

"នឹងធ្វើតាមពេលវេលាសមស្រប"[10] ។ អានុភាពនៃសាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី គឺបញ្ជាក់គាំទ្រដីកាដំណោះស្រាយ និងបញ្ជូនសំណុំរឿង០០២ ទៅអង្គជំនុំជម្រះសាលាដំបូង[11] ។

៦. នៅថ្ងៃទី១៧ ខែមករា ឆ្នាំ២០១១ មេធាវីការពារក្តីបានដាក់សំណើជាបន្ទាន់របស់ អៀង សារី សុំកុំឱ្យចាប់ផ្តើមពេលវេលាសម្រាប់បញ្ហាអញ្ញត្រកម្ម រហូតដល់ពេលដែលអង្គបុរេជំនុំជម្រះផ្តល់សំអាងហេតុទៅលើសាលដីការបស់អង្គបុរេជំនុំជម្រះ លើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ និងសំណើជាបន្ទាន់សុំបន្ថែមពេលវេលា និងបង្កើនចំនួនទំព័រកំណត់ដើម្បីដាក់បណ្តឹងអំពីអញ្ញត្រកម្ម តាមវិធាន ៨៩[12] ។ មេធាវីការពារក្តីបញ្ជាក់ថាខ្លួន "ត្រូវតែវិភាគការសំអាងហេតុរបស់អង្គបុរេជំនុំជម្រះ និងឆ្លើយតបចំពោះការភាន់ច្រឡំណាមួយនៅក្នុងការវិភាគនេះ បើសិនជាមាន ។ អញ្ញត្រកម្មដែលអាចយកជាការបាន នឹងមិនអាចធ្វើបានទេ បើសិនជាមេធាវីការពារក្តីមិនទទួលបានការសំអាងហេតុរបស់អង្គបុរេជំនុំជម្រះ ។ សិទ្ធិជាមូលដ្ឋានរបស់ អៀង សារី ក្នុងការទទួលបានការរៀបចំការពារក្តី នឹងត្រូវបានរំលោភ បើសិនជាគាត់ត្រូវបានតម្រូវឱ្យលើកអញ្ញត្រកម្ម ដោយពុំបានដឹងពីមូលហេតុដែលអង្គបុរេជំនុំជម្រះមិនទទួលយកអញ្ញត្រកម្មទាំងនេះនោះ"[13] ។

៧. នៅថ្ងៃទី ៣ ខែកុម្ភៈ ឆ្នាំ២០១១ អ្នកនាង Susan Lamb មន្ត្រីច្បាប់ជាន់ខ្ពស់នៅអង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងពីសេចក្តីសម្រេចនៅក្នុងអនុស្សរណៈអន្តរការិយាល័យ[14] ។ ការសំអាងហេតុសម្រាប់សេចក្តីសម្រេចនេះ មិនត្រូវបានផ្តល់នៅក្នុងអនុស្សរណៈអន្តរការិយាល័យនេះឡើយ បើទោះបីភាគី ត្រូវបានជូនដំណឹងថា "សេចក្តីសម្រេចរួមមួយនឹងចេញក្នុងពេលឆាប់ៗនេះ...[15]"។

---

[10] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ។

[11] វិធាន ៧៩(១) ។

[12] *ករណី អៀង សារី* ០០២/១៩-០៩-២០០៧/អវតក/អជសជ, សំណើជាបន្ទាន់របស់ អៀង សារី សុំកុំឱ្យចាប់ផ្តើពេលវេលាសម្រាប់បញ្ហាអញ្ញត្រកម្មម រហូតដល់អង្គបុរេជំនុំជម្រះផ្តល់សំអាងហេតុលើសាលាដីការបស់អង្គបុរេជំនុំជម្រះ ទៅលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ និងសំណើជាបន្ទាន់សុំបន្ថែមពេលវេលា និងបង្កើនចំនួនទំព័រកំណត់ដើម្បីដាក់បណ្តឹងអញ្ញត្រកម្ម តាមវិធាន ៨៩ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១១ E15, ERN: 00636076-00636081។

[13] ដូចខាងលើ កថាខណ្ឌទី៧ ។

[14] អនុស្សារណៈអន្តរការិយាល័យ ។

[15] ដូចខាងលើ ។

00644255



## II. ច្បាប់នៅជាធរមាន

៨. មាត្រា ១៣(១) នៃកិច្ចព្រមព្រៀងចែងថា:

សិទ្ធិរបស់ជនជាប់ចោទដែលមានចែងនៅក្នុងមាត្រា ១៤ និង១៥ នៃកតិសញ្ញាអន្តរជាតិឆ្នាំ១៩៥៦ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ត្រូវតែបានគោរពនៅទូទាំងនីតិវិធីនៃការជំនុំជម្រះក្តី ។ សិទ្ធិបែបនេះជាពិសេសរួមមានសិទ្ធិទទួលបាននូវសវនាការត្រឹមត្រូវ និងជាសាធារណៈ សិទ្ធិត្រូវបានចាត់ទុកថាគ្មានទោសពៃរ៍រហូតដល់ពេលរកឃើញថាជាប់ពិរុទ្ធ និងសិទ្ធិទទួលបានពេលវេលា និងលក្ខណៈគ្រប់គ្រាន់ ដើម្បីត្រៀមរៀបចំការការពារ សិទ្ធិទទួលបាននូវមេធាវី ប្រសិនបើជនជាប់ចោទគ្មានលទ្ធភាពជួលមេធាវីដោយខ្លួនឯង និសិទ្ធិពិនិត្យសាក្សីដាក់បន្ទុក[16] ។

៩. មាត្រា ៣៣ ថ្មី នៃច្បាប់ស្តីពីការបង្កើត អវតក ចែងក្នុងផ្នែកពាក់ព័ន្ធថា៖

អង្គជំនុំជម្រះវិសាមញ្ញរបស់សាលាដំបូងត្រូវប្រព្រឹត្តទៅឱ្យបានត្រឹមត្រូវ និងឆាប់រហ័សតាមនីតិវិធីជាធរមាន ដោយមានការគោរពយ៉ាងពេញលេញនូវសិទ្ធិរបស់ជនត្រូវចោទ និងមានការការពារឱ្យបានត្រឹមត្រូវចំពោះជនរងគ្រោះ និងសាក្សី[17]។

១០. មាត្រា ៣៥ ថ្មី នៃច្បាប់ស្តីពីការបង្កើត អវតក ចែងក្នុងផ្នែកពាក់ព័ន្ធថា៖

ក្នុងការចោទប្រកាន់មកលើខ្លួន ជនជាប់ចោទមានសិទ្ធិទទួលបាននូវការធានាជាអប្បបរមានិងស្មើៗគ្នាស្របតាមមាត្រា១៤ នៃអនុសញ្ញាអន្តរជាតិស្តីពិសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ...(ខ)មានពេលវេលានិងលក្ខណៈគ្រប់គ្រាន់ដើម្បីរៀបចំការពារខ្លួន និងទាក់ទងជាមួយមេធាវីដែលខ្លួនជ្រើសរើសដោយខ្លួនឯង...[18]។

១១. មាត្រា ១៤ (៣) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចែងក្នុងផ្នែកពាក់ព័ន្ធថា៖

ក្នុងការសម្រេចសេចក្តីចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយប្រឆាំងមកលើខ្លួន ជនគ្រប់រូបមានសិទ្ធិទទួលបានការធានាជាអប្បរិមាដោយស្មើភាពគ្នាយ៉ាងពេញលេញ៖ ... (ខ)ត្រូវមានពេលវេលា

---

[16] បញ្ជាក់បន្ថែម ។

[17] គូសបញ្ជាក់បន្ថែម។

[18] គូសបញ្ជាក់បន្ថែម។

និងសម្ភារៈរូបវន្តគ្រប់គ្រាន់សម្រាប់រៀបចំការពារខ្លួន និងឆ្លើយឆ្លងជាមួយមេធាវីដែលជ្រើសរើសដោយខ្លួនឯង...[19]។

១២. មាត្រា ១១ (១) នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សចែងថា៖ "ជនណាដែលជាប់ចោទពីបទល្មើសព្រហ្មទណ្ឌ ត្រូវសន្មតជាជនគ្មានទោស រហូតដល់ពិរុទ្ធភាពត្រូវបានរកឃើញនៅក្នុងសវនាការជាសាធារណៈដែលមានការធានាចាំបាច់ ដើម្បីការពារសិទ្ធិជនជាប់ចោទពីបទល្មើសព្រហ្មទណ្ឌ[20]"។

III. ឧទ្ទេសនាល័យ

១៣. អង្គជំនុំជម្រះសាលាដំបូងបានដាក់មេធាវីការពារក្តី ឱ្យស្ថិតក្នុងស្ថានភាពមួយដែលជៀសមិនរួចពីការទទួលយកជម្រើស Hobson[21]។ ដោយត្រូវបង្ខំចិត្តឱ្យស្មានពីការសំអាងហេតុរបស់អង្គបុរេជំនុំជម្រះក្នុងការច្រានចោលទឡ្ហីករណ៍មួយចំនួនក្នុងបណ្តឹងឧទ្ធរណ៍របស់ខ្លួន មេធាវីការពារក្តីអាចជ្រើសរើសមិនដាក់អញ្ញត្រកម្មអ្វីទាំងអស់ស្របតាមវិធាន៩៨ (១) (ក) ឬក៏ដាក់ការជំទាស់ផ្នែកយុត្តាធិការដូចគ្នា ទៅកាន់អង្គជំនុំជម្រះសាលាដំបូង ដូចដែលខ្លួនបានដាក់ទៅកាន់ កសចស ឬអង្គបុរេជំនុំជម្រះ[22] ។

១៤. មេធាវីការពារក្តីទទួលស្គាល់វិសាលភាពកាតព្វកិច្ចរបស់អង្គបុរេជំនុំជម្រះ ហើយសូមកោតសរសើរអង្គបុរេជំនុំជម្រះដែលបានអនុវត្តតួនាទីរបស់ខ្លួនដោយយកចិត្តទុកដាក់បំផុត ។ គេត្រូវការពេលវេលាដើម្បីវិភាគ និងផ្តល់សេចក្តីសម្រេចដែលមានសំអាងហេតុទាក់ទងនឹងការជំទាស់ផ្នែកយុត្តាធិការដ៏ស្មុគស្មាញ និង បកប្រែសេចក្តីសម្រេចនេះជាច្រើនភាសា។ ភាគីទាំងអស់របស់អវតក ទទួលបានសារៈប្រយោជន៍ពីការពិចារណាដ៏ហ្មត់ចត់របស់អង្គជំនុំជម្រះ ដែលធ្វើឡើងយ៉ាងប្រយ័ត្នប្រយែងដើម្បីឆ្លើយតបឱ្យទាន់កាលបរិច្ឆេទដែលគ្មានការបត់បែននោះទេ។ បើពិចារណាពី

---

[19] គូសបញ្ជាក់បន្ថែម។

[20] គូសបញ្ជាក់បន្ថែម។

[21] "ជម្រើស Hobson" ត្រូវបានគេលើកមកនិយាយជាទូទៅនៅពេលដែលជម្រើសដែលភាគីមួយគ្មានជម្រើសប្រកបដោយអត្ថន័យ។ វាត្រូវបានកំណត់ដោយវចនានុក្រម Oxford English Dictionary ថា "ត្រូវតែទទួលយកអ្វីមួយដែលគេផ្តល់ឱ្យបើមិនយកទេគឺអត់", បើចង់អាននិយមន័យបែបនេះសូមចូលទៅគេហទំព័រ http://www.oed.com/view/Entry/32111?redirectedFrom=hobson's%20choice#eid9544746

[22] បណ្តឹងឧទ្ធរណ៍។

វិសាលភាព និងភាពស្មុគស្មាញ សំណុំរឿង០០២ អាចជារឿងក្តីមួយក្នុងចំណោមរឿងក្តីដ៏ធំបំផុត នៅក្នុងប្រវត្តិសាស្ត្រច្បាប់លើពិភពលោក ។ វាគ្មានមន្ទិលសង្ស័យទេដែលថាវិសាលភាពនៃរឿងក្តី បែបនេះ មិនធ្លាប់កើតឡើងនៅកម្ពុជាឡើយ។ សម្រាប់អង្គបុរេជំនុំជម្រះ "បណ្តឹងឧទ្ធរណ៍ទាំងនេះ បានលើកឡើងនូវចំនុចជាច្រើន ដែលពីមុនមកមិនធ្លាប់ត្រូវបានគេលើកនៅចំពោះមុខតុលាការ កម្ពុជាឡើយ ហើយក្នុងករណីជាច្រើនទៀត បណ្តឹងឧទ្ធរណ៍បែបនេះមិនដែលធ្លាប់ត្រូវបានគេ យកទៅពិចារណាក្នុងច្បាប់អន្តរជាតិ និងជាពិសេសក្នុងបរិបទពេលវេលានៅ អវតក[23]"។ អ្វីដែល បានកើតក្នុងសំណុំរឿង ០០១ មិនបានផ្តល់ការណែនាំអ្វីច្រើននោះទេ។ រឿងក្តី *ទួច* គឺសវនាការលើ ការទទួលសារភាពដែលមានភាពស្មុគស្មាញ ពោលគឺ បញ្ហាច្បាប់ (ទាំងផ្នែកអង្គហេតុ និងនីតិវិធី) មិនត្រូវបានគេជំទាស់ដោយមានប្រសិទ្ធិភាពនោះទេ។ ភស្តុតាងស្ទើរតែមិនត្រូវបានគេវាយតម្លៃ ហើយដំណើរការនីតិវិធីមិនមែនជានីតិវិធីចំពោះមុខឡើយ ទោះបីជាដំណើរការនីតិវិធីនោះមាន រយៈពេលវែងក៏ដោយ។ នៅពេលថ្មីៗនេះ អង្គបុរេជំនុំជម្រះខ្លួនឯងផ្ទាល់ក៏បានអះអាងផងដែរថា "សិទ្ធិរបស់ភាគីទាំងអស់ នឹងត្រូវប៉ះពាល់យ៉ាងធ្ងន់ធ្ងរដោយការខកខានមិនបានវាយតម្លៃឱ្យបាន ត្រឹមត្រូវគ្រប់ជ្រុងជ្រោយ និងមិនបានដោះស្រាយបញ្ហាទាំងអស់ដែលបានលើកឡើងក្នុងបណ្តឹង ឧទ្ធរណ៍"[24]។

១៥. សិទ្ធិរបស់លោក អៀង សារី ដើម្បីរៀបចំការការពារ និងមានពេលវេលា និងមធ្យោបាយ គ្រប់គ្រាន់ មិនត្រូវបានប៉ះពាល់ដោយការពន្យាពេលរបស់អង្គបុរេជំនុំជម្រះក្នុងការចេញសេចក្តី សម្រេចមួយដែលមានសំអាងហេតុត្រឹមត្រូវ។ អង្គជំនុំជម្រះសាលាដំបូងរំពឹងដោយមិន សមហេតុផលថា មេធាវីការពារក្តីជាគ្រូទាយដែលអាចព្យាករណ៍ទុកជាមុន ពីការសំអាងហេតុ តាមផ្លូវច្បាប់របស់អង្គបុរេជំនុំជម្រះក្នុងការធ្វើសេចក្តីសម្រេចរបស់ខ្លួន។ ដោយមិនបានទទួល ប្រយោជន៍ពីសំអាងហេតុរបស់អង្គបុរេជំនុំជម្រះ មេធាវីការពារក្តីមិនអាចរៀបចំការពារក្តីលោក អៀង សារី ឱ្យបានជិតដល់ជាមួយពេលវេលាគ្រប់គ្រាន់ សមស្របតាមសិទ្ធិទទួលបានការ ជំនុំជម្រះក្តីដោយយុត្តិធម៌បានឡើយ។ <u>ការប៉ះពាល់ដល់លោក អៀង សារី គឺជៀសមិនផុតឡើយ</u> បើពិចារណាការដកចេញពីជម្រើស Hobson <u>ដែលអង្គជំនុំជម្រះសាលាដំបូងបានទទូចដាក់ឱ្យ</u>

---

[23] *ករណី អៀង សារី* ០០២/១៩-០៩-២០០៧/អវតក, អនុស្សារណៈអន្តរការិយាល័យបញ្ជូនពីអង្គបុរេជំនុំជម្រះឆ្លើយតបទៅនឹង អនុស្សារណៈអន្តរការិយាល័យរបស់អង្គជំនុំជម្រះសាលាដំបូងចុះថ្ងៃទី ៤ ខែកុម្ភៈ ឆ្នាំ២០១១, ថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១១, ឯកសារ D427/1/28,ERN:00641796,ទំព័រទី២។

[24] ដូចខាងលើ។

<u>មេធាវីការពារក្តីទទួលយក។</u>

១៦. វាមិនយុត្តិធម៌ទេការដែល (ក) រំពឹងឱ្យភាគីមួយដាក់អញ្ញត្រកម្មមួយឈុត ហើយដាក់តាមក្រោយនូវសារណាដែលត្រូវបានកែប្រែ ឬសារណាបន្ថែម បន្ទាប់ពីអង្គបុរេជំនុំជម្រះចេញសំអាងហេតុរបស់ខ្លួននោះ និង(ខ) រំពឹងឱ្យអង្គភាពបកប្រែឯកសារ នឹងបកប្រែសំណេរ ("ITU") បកប្រែសារណាចំនួនពីរនៅពេលដែលសារណាតែមួយប៉ុណ្ណោះដែលចាំបាច់ ទោះបីជាអង្គភាព ITU បានប្រើអស់ធនធានរបស់ខ្លួនក៏ដោយ[25]។ ឧបមាថា តាមពិតអង្គជំនុំជម្រះសាលាដំបូងអនុញ្ញាតអោយទុកពេលវេលា និងទំព័រតាមការកំណត់ដើម្បីដាក់អញ្ញត្រកម្មថ្មី ឬបំពេញបន្ថែមប្រកបដោយអត្ថន័យ លទ្ធផលនៃសេចក្តីសម្រេចនេះទំនងជាតម្រូវឱ្យភាគី និង ITU ធ្វើការទ្វេរដង និងប្រហែលតម្រូវឱ្យអង្គជំនុំជម្រះសាលាដំបូងពិចារណាទ្វេរដងលើសារណាជាច្រើន ព្រោះតែការមិនគោរពតាមវិធានប្បញ្ញត្តិបានកើតឡើង។ ការមិនយកចិត្តទុកដាក់លើការសន្សំសំចៃរបស់តុលាការបែបនេះ មិនត្រឹមតែប៉ះពាល់ដល់ធនធាន និងពេលវេលាដ៏មានតម្លៃទេ ប៉ុន្តែជាការរំលោភដល់សិទ្ធិលោក អៀង សារី ក្នុងការទទួលបានការជំនុំជម្រះក្តីដោយឆាប់រហ័សផងដែរ[26]។

**អាស្រ័យហេតុនេះ** ដូចហេតុផលដែលបានបញ្ជាក់នៅទីនេះ មេធាវីការពារក្តីសូមស្នើឱ្យអង្គជំនុំជម្រះសាលាដំបូងមេត្តា៖

ក. ចេញសេចក្តីសម្រេចដែលមានសំអាងហេតុលើអញ្ញត្រកម្មនេះជាបន្ទាន់

ខ. ធ្វើមោឃៈភាពលើសេចក្តីសម្រេចនេះ និង

គ. ផ្តល់ឱ្យភាគីនូវពេលវេលា និងចំនួនទំព័រគ្រប់គ្រាន់ដើម្បីដាក់អញ្ញត្រកម្មបន្ថែម ឬអញ្ញត្រកម្មថ្មីបន្ទាប់ពីអង្គបុរេជំនុំជម្រះ ចេញសំអាងហេតុរបស់ខ្លួន ។

---

[25] អង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់ថាអង្គភាពអ្នកបកប្រែមានការលំបាកក្នុងការបកប្រែឯកសារឱ្យទាន់ពេលកំណត់។ សូមមើលករណីលោក នួន ជា សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក-អជសដ,អនុស្សារណៈរបស់ អជសដ ទៅកាន់ DOA និងDDOA ទាក់ទងនឹងការរាំងស្ទះក្នុងការបកប្រែនៅចំពោះមុខ អជសដ ក្នុងសំណុំរឿង០០២ និតតំណែងទំនេរនៅអង្គភាពអ្នកបកប្រែ ចុះថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១១, ឯកសារ E38.1,ENR:00642944-00642945។

[26] សូមមើល ច្បាប់បង្កើត អវតក មាត្រា ៣៣ ថ្មី។

00644259



សូមចៅក្រមអង្គជំនុំជម្រះសាលាដំបូងទទួលយកសំណើនេះដោយក្តីគោរព។

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១១

ANG Udom Michael G. KARNAVAS

អាង ឧត្តម Michael G. KARNAVAS

សហមេធាវីរបស់លោក អៀង សារី